ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

# សេចក្ដីប្រកាសព័ត៌មាន
## ស្ដីពីការចេញផ្សាយនៅលើគេហទំព័ររបស់សារព័ត៌មាន Vice ក្រោមចំណងជើងថា
## "These People Were Arrested by the Khmer Rouge and Never Seen Again"

ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០២១

ក្រសួងពាណិជ្ជកម្ម ក្នុងនាមប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា មានកិត្តិយសសូមគោរពជម្រាបជូន សម្ដេច ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា និងសាធារណជនទាំងអស់ មេត្តាជ្រាបថា កាលពីថ្ងៃទី៩ ខែមេសា ឆ្នាំ២០២១ លោក Matt Loughrey ជនជាតិអៀរឡង់ បានចេញផ្សាយអត្ថបទ ក្រោមចំណងជើងថា "These People Were Arrested by the Khmer Rouge and Never Seen Again" នៅក្នុងគេហទំព័ររបស់សារព័ត៌មាន Vice។ ការផ្សាយអត្ថបទនេះ បានផ្សព្វផ្សាយរូបថតជនរងគ្រោះនៅអតីតមន្ទីរសន្តិសុខ ស២១ (បច្ចុប្បន្នជាសារមន្ទីរគុកទួលស្លែង) ដោយបានកែច្នៃរូបថតទៅជាពណ៌ធម្មជាតិ និងរូបជនរងគ្រោះមានស្នាមញញឹមខុសពីរូបភាពដើម ហើយជនរងគ្រោះមានរូបភាពតក់ស្លុត ព្រោះស្ថិតក្នុងស្ថានភាពនៃការគំរាមកំហែង និងទទួលទារុណកម្មយ៉ាងឃោរឃៅ និងព្រៃផ្សៃបំផុត ពីសំណាក់បនប្រល័យពូជសាសន៍ប៉ុលពត។

ក្រសួងពាណិជ្ជកម្មសូមថ្កោលទោសយ៉ាងដាច់អហង្ការចំពោះទង្វើអគតិនេះ ពីព្រោះគឺជាការបំភ្លៃប្រវត្តិសាស្ត្ររបស់ព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កិត្តិយស និងភាពថ្លៃថ្នូររបស់ជនរងគ្រោះដែលបានបាត់បង់ជីវិតរួចទៅហើយ និងក្រុមគ្រួសាររបស់ជនរងគ្រោះ ព្រមទាំងធ្វើឱ្យមានការឈឺចាប់ និងខ្លោចផ្សាក្រៃលែងដល់ប្រជាជនកម្ពុជាទាំងអស់ ជាពិសេសប្រជាជនដែលបានឆ្លងកាត់របបបនប្រល័យពូជសាសន៍ប៉ុលពត។

លើសពីនេះទៀត ទង្វើបែបនេះមិនត្រឹមតែបានរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើសិទ្ធិសីលធម៌របស់អ្នកនិពន្ធក្រោមច្បាប់ស្ដីពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល របស់ព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែថែមទាំងបានរំលោភបំពានលើការប្រើប្រាស់រូបភាពរបស់សារមន្ទីរ និងសិទ្ធិមនុស្ស ដូចមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន រួមមាន ច្បាប់បណ្ណសាររបស់ព្រះរាជាណាចក្រកម្ពុជា ព្រមទាំងអនុសញ្ញា និងសន្ធិសញ្ញានានារបស់អង្គការសហប្រជាជាតិពាក់ព័ន្ធនឹងសិទ្ធិមនុស្សផងដែរ។ ទង្វើបែបនេះ ក៏បានរំលោភបំពានលើកិច្ចព្រមព្រៀងអន្តរជាតិនានាដែលកម្ពុជា និងប្រទេសអៀរឡង់ជាភាគីផងដែរ រួមមាន កិច្ចព្រមព្រៀងទិដ្ឋភាពពាណិជ្ជកម្មពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា និងអនុសញ្ញាទីក្រុងប៊ែន ស្ដីពីកិច្ចការពារស្នាដៃអក្សរសាស្ត្រ និងស្នាដៃសិល្បៈ ជាដើម។

ក្រសួងពាណិជ្ជកម្មនឹងសហការជិតស្និទ្ធជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីពិនិត្យលើទិដ្ឋភាពផ្លូវច្បាប់ជាតិ និងអន្តរជាតិ ដើម្បីចាត់វិធានការចំពោះករណីនេះ។

ថ្ងៃចន្ទ ១កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១២ ខែមេសា ឆ្នាំ២០២១

ឡូតិ៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ទូរសព្ទ/ទូរសារ៖ (៨៥៥) ២៣ ៨៦៦ ៤៦៩
Lot 19-61 Russian Federation Blvd., Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Fax: (855) 23 866 469